# កិច្ចសំណេះសំណាលជាមួយគណៈកម្មាធិការអេដស៍ខេត្តក្រចេះ

កាលពីព្រឹកថ្ងៃទី ០៣ ធ្នូ ឆ្នាំ ២០១៣ នៅមន្ទីរសុខាភិបាលខេត្តក្រចេះ មានរៀបចំពិធីសំណេះសណាល ជាមួយសមាជិកសមាជិកាគណៈកម្មាធិការខេត្តប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តក្រចេះ ក្រោមអធិបតីភាព **លោកទេស រដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ជាដំបូង **លោកវេជ្ជបណ្ឌិត ឈ្នាង សុវត្ថា** ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តក្រចេះ សំដែងការស្វាគមន៍ចំពោះគណៈប្រតិភូ និង អបអរសាទរចំពោះការចូលរួមសមាជិកសមាជិកា ដែលមានអភិបាលរងខេត្ត អភិបាលរងស្រុក មេឃុំ សង្កាត់ អង្គការក្រៅរដ្ឋាភិបាល ។ **លោក ខូវ បានលី** អនុប្រធានលេខាធិការដ្ឋាន បានរាយការណ៍ជូនអង្គប្រជុំអំពីសកម្មភាពការងារដែលលេខាធិការដ្ឋានធ្វើក្នុងនាមគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្តក្រចេះ ដោយបានបញ្ជាក់ថាកម្មវិធីអេដស៍ ឆ្នាំ២០១៣ របស់ខេត្ត មានស្រុកប្រតិបត្តិ ២ គឺ ខេត្តក្រចេះ និង ឆ្លូង, មានមន្ទីរពេទ្យបង្អែក ៣ គឺ ក្រចេះ ឆ្លូង នឹង ស្នួលមានមណ្ឌលសុខភាព ចំនួន ២៩, ប៉ុស្តិ៍សុខភាព ១២, មណ្ឌលធ្វើតេស្ត ០៦, មណ្ឌលព្យាបាលជំងឺឪកាសនិយម ០១, គ្លីនិកសុខភាពគ្រួសារមាន ០១ កំពុងដំណើរការ ។ អ្នកស្ម័គ្រចិត្តមកធ្វើតេស្តឈាមចំនួន ១១២០ នាក់ ក្នុងនោះ ស្ត្រី ៧៨៣ នាក់ ឯចំនួនអ្នកធ្វើតេស្តវិជ្ជមាន ១៣ នាក់ ក្នុងនោះស្ត្រី ០៨នាក់ (តួលេខគិតត្រឹមចុងត្រីមាសទី ៣ ) ។ **លោកទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានកោតសរសើរចំពោះសមិទ្ធផល និង បានលើកទឹកចិត្តអោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ព្រមទាំងលេខាធិការដ្ឋានបន្តខិតខំបំពេញភារកិច្ចនេះតទៅទៀត។ **លោកទេសរដ្ឋមន្ត្រី** បានលើកយកចំណុចនយោបាយសំខាន់ៗនៃការប្រយុទ្ធនឹងជំងឺអេដស៍របស់រាជរដ្ឋាភិបាលជាពិសេសការផ្សព្វផ្សាយអោយមានការស្ម័គ្រចិត្តមកធ្វើតេស្តមេរោគអេដស៍ និង អោយមានការប្រើប្រាស់ស្រោមអនាម័យអោយបានទូលំទូលាយ ដើម្បីទប់ស្កាត់ការឆ្លង និង រីករាលដាលនៃជំងឺអេដស៍ ។ ជាមួយនោះលោកក៏បានណែនាំអោយរៀបចំជាផែនទីបញ្ជាក់ពីភូមិសាស្ត្រ និង ចំនួនពិតប្រាកដនៃអ្នកផ្ទុកមេរោគអេដស៍ ស្ត្រីបំរើសេវាកំសាន្ត បុរសស្រឡាញ់បុរស និង ទីកន្លែងផ្តល់សេវាព្យាបាលជំងឺអេដស៍ ។ ល៕